ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
**<u>នាយកដ្ឋានព័ត៌មាន</u>**

# សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យ
# ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

វាជារឿងគួរឲ្យភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលថា "សមាជិកសភាសហភាពអឺរ៉ុប" មួយចំនួនតូច តាមរយៈសេចក្តីរាយការណ៍ បានឲ្យដឹងពីបំណងរបស់ពួកគេក្នុងការហែហមទណ្ឌិតរត់គេចខ្លួន សម រង្ស៊ី ដែលប្រកាសដដែលៗពីការវិលត្រលប់របស់ខ្លួនមកកម្ពុជាវិញក្នុងកាលបរិច្ឆេទមួយមិនច្បាស់លាស់។

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សូមរំលឹកឡើងវិញថា ទណ្ឌិត សម រង្ស៊ី ត្រូវបានទទួលការចោទប្រកាន់ និងកាត់ទោសឲ្យជាប់ពន្ធនាគារជាច្រើនករណី ដែលមានជាអាទិ៍ អំពើក្បត់ជាតិ បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ បទប្រមាទចំពោះអង្គ**ព្រះមហាក្សត្រ នរោត្តម សីហមុនី** បទញុះញុងមិនឲ្យយោធិនស្តាប់បញ្ជា ។ល។

នៅក្នុងបរិបទនេះ បើប្រសិនជាមានការអនុវត្តបែបនេះពីសំណាក់សមាជិកសភាសហភាពអឺរ៉ុបមួយចំនួនតូចអស់ទាំងនោះ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សូមសម្តែងនូវការខកចិត្តយ៉ាងខ្លាំង និងចាត់ទុកទង្វើអស់ទាំងនេះ ជាទង្វើគ្មានលក្ខណៈការទូត មិនគោរពអធិបតេយ្យភាព និងនីតិរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយនឹងការស្វាគមន៍ដល់ភ្ញៀវបរទេសគ្រប់រូបទាំងអស់ដែលគោរពច្បាប់ មានបំណងល្អ និងស្មោះត្រង់ក្នុងការលើកកម្ពស់ចំណងមិត្តភាព ទំនាក់ទំនងប្រជាជននិងប្រជាជន និងកិច្ចសហប្រតិបត្តិការដែលផ្តល់ប្រយោជន៍ទៅវិញទៅមក ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចាំបាច់ត្រូវក្រើនរំលឹកដល់សមាជិកសភាសហភាពអឺរ៉ុបមួយចំនួនតូចអស់ទាំងនោះ ពីច្បាប់ស្តីពីអន្តោប្រវេសន៍កម្ពុជា ឆ្នាំ១៩៩៤ ដែលចែងអំពីកាតព្វកិច្ចដែលត្រូវបំពេញមុនចូលប្រទេសកម្ពុជា ការអនុញ្ញាតឲ្យចូលត្រូវ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 [illegible] / 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

គិតគូរពីសន្តិសុខជាតិ និងផលវិបាកចំពោះការចូលដោយលបលាក់ បន្លំ ឬដោយមធ្យោបាយខុសច្បាប់ផ្សេងទៀត ដែលផ្ទុយនឹងច្បាប់ជាធរមានរបស់កម្ពុជា។

លើសពីនេះទៀត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមរំលឹកសមាជិកសភាសហភាពអឺរ៉ុបអស់ទាំងនោះ ពីមាត្រា៤១ នៃសន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត ដែលតម្រូវឲ្យបុគ្គលទាំងអស់ "ដែលទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះ។ បុគ្គលទាំងនោះក៏មានកាតព្វកិច្ចមិនត្រូវជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋម្ចាស់ផ្ទះផងដែរ។"

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមស្នើយ៉ាងទទូចដល់អ្នកនយោបាយបរទេសខាងលើអស់ទាំងនោះ ពិចារណាឡើងវិញពីការសម្រេចចិត្តដោយខ្វះព័ត៌មានច្បាស់លាស់ និងត្រូវបញ្ឈប់ជាបន្ទាន់នូវទង្វើដែលបង្កប់ដោយឧបាយកលនយោបាយ និងគ្មានលក្ខណៈការទូត។ ម្យ៉ាងវិញទៀត ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សូមអះអាងសារជាថ្មីនូវការប្តេជ្ញាចិត្តឥតងាករេរបស់កម្ពុជាក្នុងការលើកកម្ពស់នីតិរដ្ឋ និងក្នុងការថែរក្សាសន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ដែលប្រជាជនកម្ពុជាកំពុងទទួលបានសព្វថ្ងៃនេះ។

ថ្ងៃសៅរ៍ ៥កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៩